សាលាឧទ្ធរណ៍បាត់ដំបង

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១២៩

ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២

**សាលដីកា**

លេខ:៤៨៣ (ខ)

ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# តាមនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍បាត់ដំបង

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស០១៥/០៧១៤/រកម/ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និង ព្រះរាជក្រឹត្យលេខ នស/រតក/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

**ឯកឧត្តម** [redacted] **ប្រធានក្រុមប្រឹក្សា**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

## តំណាងមហាអយ្យការ

**ឯកឧត្តម** [redacted] **អគ្គព្រះរាជអាជ្ញារង**

## ក្រឡាបញ្ជីសវនាការ

**លោក** [redacted] **ក្រឡាបញ្ជី**

ដើម្បីពិភាក្សាដេញដោលលើសំណុំរឿងព្រហ្មទណ្ឌលេខ ១២៩ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] ហឿ ភេទស្រី កើតនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៥៩ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅ [redacted] មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លាប់) ប្តីឈ្មោះ [redacted] មានកូន០៥នាក់ ជានីតិជន ទោសពីមុនគ្មាន។ **(ក្រៅឃុំ)**

២.ឈ្មោះ ឆាន់ ហូវ ភេទប្រុស ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ន នៅភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។ **(ក្រៅឃុំ)**



ស្កេនជាមួយ CamScanner

៣.ឈ្មោះ [redacted] ហ៊ាន ភេទប្រុស ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្ន [redacted]។ (ក្រៅឃុំ)

៤.ឈ្មោះ [redacted] ហ៊ួង ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្ន [redacted]។ (ក្រៅឃុំ)

៥.ឈ្មោះ [redacted] ស្រីពៅ ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្នភូមិ [redacted]។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ លួច បានប្រព្រឹត្តនៅចំណុចភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង បទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

-ដោយមានលោក [redacted] វ៉ាន់ដេត ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡា ភេទស្រី អាយុ៥៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិទួលបល្ល័ង្ក ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។

## ដំណើររឿងហេតុមានដូចតទៅ

កាលពីអំឡុងឆ្នាំ២០១៩ នៅចំណុចភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង មានករណី លួច បានកើតឡើង ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] ហឿ ភេទស្រី ជនជាប់ចោទឈ្មោះ [redacted] ហូវ ភេទប្រុស ជនជាប់ចោទឈ្មោះ [redacted] ហូវ ភេទប្រុស ជនជាប់ចោទឈ្មោះ [redacted] ហ៊ាន ភេទប្រុស ជនជាប់ចោទឈ្មោះ [redacted] ហ៊ួង ភេទស្រី និងជនជាប់ចោទឈ្មោះ [redacted] ស្រីពៅ ភេទស្រី បាននាំគ្នាធ្វើសកម្មភាពចូលក្នុងផ្ទះរបស់ជនរងគ្រោះឈ្មោះ [redacted] ឡា ភេទប្រុស និងលួចយកទ្រព្យសម្បត្តិនៅក្នុងផ្ទះមានដូចជាៈ គ្រែបេងចំនួន០១ គ្រែធម្មតាចំនួន១ ហិបដាក់ខោអាវចំនួន១ ធុងដាក់ទឹកកកចំនួន១ ម៉ាស៊ីនបាញ់ថ្នាំចំនួន១ ម៉ាស៊ីនបូមទឹកចំនួន១ ទីយ៉ូបូមទឹកចំនួន១ និងសម្ភារៈមួយចំនួនទៀតនៅក្នុងផ្ទះ និងបានលួចដកដំឡូងមីរបស់ជនរងគ្រោះ ដាំអស់ទំហំ២ ហិចតា ដកយកទាំងអស់គ្មានសល់។

**-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ ៨៧៨ "ច" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ**

១-ផ្តន្ទាទោសដាក់ពន្ធនាគារលើៈ

១.១.ឈ្មោះ [redacted] ហឿ ភេទស្រី កើតឆ្នាំ១៩៥៩ (មានអត្តសញ្ញាណជាតិដូចខាងលើ)

១.២.ឈ្មោះ [redacted] ហូវ ភេទប្រុស (មានអត្តសញ្ញាណជាតិដូចខាងលើ)

១.៣.ឈ្មោះ [redacted] ហ៊ាង ភេទប្រុស (មានអត្តសញ្ញាណជាតិដូចខាងលើ)

១.៤.ឈ្មោះ [redacted] ហ៊ួង ភេទស្រី (មានអត្តសញ្ញាណជាតិដូចខាងលើ)

១.៥.ឈ្មោះ [redacted] ស្រីពៅ ភេទស្រី (មានអត្តសញ្ញាណជាតិដូចខាងលើ)

ក្នុងម្នាក់ៗកំណត់រយៈពេល ១០(ដប់)ខែ ពីបទ "លួច" តាមបញ្ញត្តិមាត្រា ៣៥៣ , ៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីកំឡុងឆ្នាំ២០១៩។

២-ទុកសិទ្ធិឲ្យជនរងគ្រោះ ប្តឹងទាមទារសំណងលើការខូចខាត ក្នុងរឿងរដ្ឋប្បវេណី។



ស្កេនជាមួយ CamScanner

សេចក្តីសម្រេចនេះ ប្រកាសដោយចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហឿ ជនជាប់ចោទឈ្មោះ [redacted] ហួរ ជនជាប់ចោទឈ្មោះ ឆាន់ ហ៊ាន ជនជាប់ចោទឈ្មោះ [redacted] ហ៊្វង ជនជាប់ចោទឈ្មោះ ឆាន់ ស្រីពៅ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡា ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកាលកំណត់នៃច្បាប់ ។

-បានឃើញៈ ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ហួរ ឈ្មោះ [redacted] ស្រីពៅ ឈ្មោះ [redacted] ហ៊ាន ឈ្មោះ [redacted] ហ៊្វង ឈ្មោះ [redacted] ហឿ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៧៨ "ច" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុច សេចក្តីសម្រេចទាំងមូល ។

-បានឃើញៈ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ ។

-បានឃើញៈ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ ។

## **នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ហួរ ឈ្មោះ [redacted] ស្រីពៅ ឈ្មោះ [redacted] ហ៊ាន ឈ្មោះ [redacted] ហ៊្វង (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] ហឿ (អវត្តមាន)

-លោក [redacted] ភ៉ាន់ដេត ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡា (វត្តមាន)

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះសង្ខេបរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ [redacted] ហ្វង បានឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ព្រោះផ្ទះរបស់ខ្លួនរស់នៅយូរមកហើយ។ ខ្លួនបានរស់នៅតាំងពីឆ្នាំ១៩៩៦ ខ្លួនរស់នៅផ្ទះរបស់ខ្លួនឯង នៅក្នុងផ្ទះមានគ្រែ មានចានឆ្នាំង ហើយខ្លួនមិនបានរើផ្ទះទេ ឈ្មោះ [redacted] ឡា ជាអ្នករើ ហើយឈ្មោះ [redacted] ឡា គ្មានផ្ទះទេ ផ្ទះនេះម៉ែជាអ្នកធ្វើ ហើយរស់នៅជុំគ្នា មួយគ្រួសារ។ ខ្លួនសំណូមពរលើកលែងការចោទប្រកាន់។

-ជនជាប់ចោទឈ្មោះ [redacted] ស្រីពៅ ខ្លួនមិនបានចូលលួចគេទេ មានតែគេរុះរើផ្ទះរបស់ខ្លួន។

-ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា ដីរបស់ខ្លួន ផ្ទះខ្លួនបានសាងសង់ពីឆ្នាំ២០១១ ហើយបិទរបងមិនឱ្យចូលទេ។ ទ្រព្យសម្បត្តិនៅក្នុងផ្ទះទាំងអស់។ ខ្លួនបានធ្វើផ្ទះហើយបានចេញទៅរកស៊ី ទៅធ្វើការរោងចក្រ ពួកគេចូលទៅយកនៅឆ្នាំ២០១៩ ហើយខ្លួនបានដាក់ពាក្យបណ្តឹងដែរ។ ផ្ទះរបស់ខ្លួនចំណែកដីក៏ជារបស់ខ្លួនដែលមានបង្កាន់ដៃទិញលក់ពីភូមិឃុំ ។ ផ្ទះរបស់ខ្លួនមានទំហំ ៤(បួន) គុណ ៥(ប្រាំ)ម៉ែត្រ។ មានរោងគោ មានគ្រែពីរ ធុងទឹកកកធំ ម៉ាស៊ីនបូមទឹក ក្បាលបូមចាប់ជាមួយគោយន្ត ខ្លួនមិនមានពេលវេលាតាមដានមើលទេ ហើយខ្លួនសន្និដ្ឋានថា មានតែពួកគេអ្នកយក។ ផ្ទះរបស់ខ្លួននោះគេរើជំបូល ជញ្ជាំងនៅ ខ្លួនបានលួចចូលទៅមើលគ្មានសល់អីវ៉ាន់ទេ ខ្លួនបានឃើញគេរើផ្ទះ ដីនោះខ្លួនបានទិញពីគេ ក្នុងឆ្នាំប្រហែលជា២០១១ ឈើធ្វើផ្ទះបានពីឪពុក ។ ក្នុងឆ្នាំ២០១៩ ពេលនោះឃើញគេយកផ្ទះភ្លាមខ្លួនបានដាក់ពាក្យបណ្តឹងភ្លាម។ ខ្លួនចេញពីផ្ទះបានពីរខែ គេយកផ្ទះបាត់។ ខ្លួនសំណូមពរចុងក្រោយសុំឱ្យគេចេញពីផ្ទះវិញ និងទុករបស់ឱ្យខ្លួនវិញ។



ស្កេនជាមួយ CamScanner

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការពិភាក្សាដេញដោល និងពិនិត្យសំណុំរឿងកើតចេញពីទំនាស់ដណ្តើមដីគ្នា ចំណែកផ្ទះអាជ្ញាធរបញ្ជាក់ថាផ្ទះរបស់ឈ្មោះ [redacted] ឡា ដូច្នេះតំណាងមហាអយ្យការ ស្នើសុំឱ្យក្រុមប្រឹក្សាតម្កល់សាលក្រមសាលាដំបូងទុកជាបានការ ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីការសួរដេញដោលឃើញថាកូនក្តីខ្លួនត្រូវចោទ ទាក់ទងឯកសារក្លែង ឯកសារនេះត្រឹមត្រូវអត់ក្លែងទេ ។ ពាក់ព័ន្ធដីកូនក្តីខ្លួន នៅគ្រប់គ្រងហើយមានចុះពិនិត្យ វាយតម្លៃ ។ រឿងនេះអង្គហេតុឆបោកអត់មានសោះតែម្តង ។ ហេតុនេះសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះពិនិត្យជាគុណប្រយោជន៍ចំពោះជនជាប់ចោទ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពររបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង

## យល់ឃើញថា

១.ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ហឿ , [redacted] ហូវ, [redacted] ហ៊ាន, [redacted] ហួង និង [redacted] ស្រីពៅ ធ្វើឡើងតាមកំណត់ច្បាប់សាលាឧទ្ធរណ៍បាត់ដំបងទទួលជំនុំជម្រះបានយោងតាមបញ្ញត្តិមាត្រា ៣៨២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.កាលពីអំឡុងឆ្នាំ២០១៩ ជនជាប់ចោទឈ្មោះ [redacted] ហឿ, [redacted] ហូវ, [redacted] ហ៊ាន, [redacted] ហួង និង [redacted] ស្រីពៅ បានចូលទៅរុះរើផ្ទះរបស់ឈ្មោះ [redacted] ឡា ស្ថិតនៅភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ក្នុងពេលឈ្មោះ [redacted] ឡា ដែលជាម្ចាស់ផ្ទះពុំនៅផ្ទះរវល់ដឹកច្បូងដើរលក់ដោយបានយកទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] ឡា មួយចំនួន។

៣.ជនជាប់ចោទឈ្មោះ [redacted] ហឿ, [redacted] ហូវ, [redacted] ហ៊ាន, [redacted] ហួង និង [redacted] ស្រីពៅ បានឆ្លើយប្រហាក់ប្រហែលគ្នាថា ខ្លួនមិនបានលួចយកទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] ឡា ទេ ខ្លួនបានចូលទៅធ្វើផ្ទះលើដីនោះក្នុងឆ្នាំ២០១១។ ខ្លួនមិនបានជញ្ជូនគ្រែ និងទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] ឡា ទេ។

៤.តាមចម្លើយបំភ្លឺរបស់សាក្សី និងតាមការបំភ្លឺរបស់អាជ្ញាធររបស់មូលដ្ឋានបានបញ្ជាក់ឱ្យឃើញថាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡា បានសង់ផ្ទះរស់នៅលើទីតាំងនេះយូរមកហើយ។ ក្រោយមកទើបក្រុមជនជាប់ចោទបានរំលោភចូលទៅរុះរើផ្ទះ និងយកទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] ឡា និងបានហាមឃាត់ឈ្មោះ [redacted] ឡា ដែលជាម្ចាស់ផ្ទះមិនឱ្យចូលទៅក្នុងបរិវេណដី និងផ្ទះទៀតផង។

៥.តាមចម្លើយរបស់ជនជាប់ចោទ តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី តាមការបំភ្លឺរបស់សាក្សី និងតាមឯកសារភស្តុតាងក្នុងសំណុំរឿងបានបញ្ជាក់ឱ្យឃើញថាក្រុមជនជាប់ចោទពិតជាបានចូលទៅរុះរើផ្ទះ និងលួចយកទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] ឡា ប្រាកដមែន។



ស្កេនជាមួយ CamScanner

៦.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ហឿ, [redacted] ហូវ, [redacted] ហ៊ាន, [redacted] ហួង និង [redacted] ស្រីពៅ ពីបទលួច ប្រព្រឹត្តនៅភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីអំឡុងឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៦ នៃ ក្រមព្រហ្មទណ្ឌ។

៧.រឿងក្តីនេះសាលាដំបូងខេត្តបាត់ដំបងបានធ្វើការអង្កេត និងលើកយកភស្តុតាងមកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍បាត់ដំបងឯកភាពលើសំអាងហេតុនេះ ដូច្នេះសាលាឧទ្ធរណ៍បាត់ដំបងពុំចាំបាច់លើយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ។

៨.តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានធ្វើសេចក្តីសន្និដ្ឋានថានៅក្នុងអង្គហេតុនេះ គឺមានសាក្សីដែលជាអាជ្ញាធរបានបញ្ជាក់ច្បាស់លាស់ថាផ្ទះគឺជារបស់ដើមបណ្តឹងឈ្មោះ [redacted] ឡា ហើយជនជាប់ចោទពិតជាបានចូលទៅរុះរើផ្ទះ និងលួចយកទ្រព្យសម្បត្តិរបស់ដើមបណ្តឹងពិតមែន។ តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងប្តឹងសុំ ឱ្យក្រុមប្រឹក្សាជំនុំជម្រះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបងធ្វើការពិនិត្យ និងពិចារណាសម្រេចទៅតាមនីតិវិធីច្បាប់។

៩.សាលក្រមព្រហ្មទណ្ឌលេខ ៨៧៨ "ច" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបងដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល។

## **<u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>**

១.ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០ខែធ្នូ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ហឿ, [redacted] ហូវ, [redacted] ហ៊ាន [redacted] ហ្លួង និងឈ្មោះ [redacted] ស្រីពៅ ទុកថាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់។

២.តម្កល់ សាលក្រមព្រហ្មទណ្ឌលេខ ៨៧៨ "ច" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល។

៣.សាលដីកានេះប្រកាសជាសាធារណៈ នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា៖ [redacted] | ហត្ថលេខា៖ [redacted] | ហត្ថលេខា៖ [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ២រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

បាត់ដំបង ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



ស្កេនជាមួយ CamScanner